## សេវាកម្មសម្រាប់ជនរងគ្រោះនៃការជួញដូរ

DOL អាចជួយជនរងគ្រោះនៃការជួញដូរមនុស្ស ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍ ដោយផ្តល់សេវាកម្មផ្សេងៗ ឬបញ្ជូនបន្តទៅកាន់បណ្តាអង្គការសហគមន៍នានា។

សេវាកម្មទាំងនេះរួមមាន៖

- ការផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្នបន្ទាន់
- អាហារ និងតម្រូវការមូលដ្ឋានផ្សេងទៀត
- ការទារប្រាក់ឈ្នួលដែលមិនទាន់បើក
- ការបណ្តុះបណ្តាលលើជំនាញការងារ និងការរកកន្លែងឲ្យធ្វើការ
- ជំនួយផ្នែកច្បាប់ និងអន្តោប្រវេសន៍
- ជំនួយក្នុងការបង្កើតស្ថានភាពនៃការស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងសហរដ្ឋអាមេរិក
- សេវាសុខភាពផ្លូវចិត្ត និងផ្លូវកាយ
- ការប្រឹក្សាយោបល់
- ជួយឲ្យទទួលបានអត្ថប្រយោជន៍សាធារណៈរបស់សហព័ន្ធ និងរដ្ឋ
- ការបកប្រែអត្ថបទ និងការបកប្រែផ្ទាល់មាត់
- បណ្តឹងឧក្រិដ្ឋកម្ម និង/ឬបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងអ្នកជួញដូរ



ដើម្បីរាយការណ៍ករណីសង្ស័យពីបទជួញដូរមនុស្ស សូមទំនាក់ទំនង៖

**នាយកដ្ឋានអនុលោមភាព និងអប់រំនៃក្រសួងការងាររដ្ឋញូវយ៉ក (ពីមុនហៅថានាយកដ្ឋានគោលនយោបាយ និងកិច្ចការអន្តោប្រវេសន៍)**

ទូរសព្ទ៖ **877-466-9757**

អ៊ីមែល៖ **trafficking@labor.ny.gov**

វេបសាយ៖ **www.labor.ny.gov/immigrants**

**ផ្នែកជួញដូរមនុស្សថ្នាក់ជាតិ**
**មជ្ឈមណ្ឌលធនធាន**

ទូរសព្ទ៖ **888-373-7888**

**ធនធានបន្ថែម៖**

**គម្រោង Polaris**៖ www.polarisproject.org

**ក្នុងករណីអាសន្ន សូមហៅទៅលេខ 911 ភ្លាមៗ។**

WE ARE YOUR DOL

NEW YORK STATE | Department of Labor

@nyslabor | www.labor.ny.gov
1-888-469-7365

ក្រសួងការងារនៃរដ្ឋញូវយ៉កគឺជានិយោជក/កម្មវិធី ដែលផ្តល់ឱកាសស្មើភាព។ មានផ្តល់ជំនួយ និងសេវាកម្មគាំទ្រតាមការស្នើសុំ និងមិនគិតថ្លៃចំពោះបុគ្គលមានពិ TTY/TDD 711 ឬ 1-800-662-1220 ព្រ ្រគឹស / 1-877-662-4886។

P744KH (02/24)







# ពលកម្មទាំងបង្ខំ
# គឺជាឧក្រិដ្ឋកម្ម

## ជំនួយសម្រាប់ជនគ្រោះនៃការជួញដូរមនុស្ស

WE ARE YOUR DOL

NEW YORK STATE | Department of Labor

## តើពលកម្មទាំងបង្ខំគឺជាអ្វី?

ពលកម្មទាំងបង្ខំដែលហៅម្យ៉ាងទៀតថា "ការជួញដូរមនុស្ស" គឺជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។ មនុស្សដែលត្រូវបានគេជួញដូរប្រហែលជាមិនដឹងថាអ្វីដែលកំពុងកើតឡើងចំពោះពួកគេគឺជាអំពើខុសច្បាប់ ហើយមានផ្តល់ជំនួយនោះទេ។ **ការជួញដូរពលកម្មកើតឡើង នៅពេលដែលជនម្នាក់ប្រើកម្លាំង ការក្លែងបន្លំ ឬការបង្ខិតបង្ខំដើម្បីអន្ទងឲ្យអ្នកដទៃធ្វើការខុសពីឆន្ទៈរបស់ខ្លួន។**

**កម្លាំង៖** ការគំរាមកំហែងនៃអំពើហិង្សាផ្លូវកាយ ឬអំពើហិង្សាផ្លូវកាយ ដាក់ស្តែងទៅលើកម្មករ ឬក្រុមគ្រួសាររបស់ពួកគេ។

**ការក្លែងបន្លំ៖** ការសន្យាខ្យល់ដែលឈ្មួញជួញដូរមិនមានបំណង ធ្វើតាមសន្យាទេ ដូចជាសន្យាផ្តល់បណ្ណបៃតង ឬលុយ។

**ការបង្ខិតបង្ខំ៖** ការគំរាមកំហែងដែលធ្វើឡើងដើម្បីបង្ខំនរណាម្នាក់ ឱ្យធ្វើការ ដូចជាការគំរាមកំហែងប្តឹងទៅសមត្ថកិច្ចផ្នែកអន្តោប្រវេសន៍ ឬប៉ូលិស ហើយចោទប្រកាន់ដោយមិនពិតពីបទឧក្រិដ្ឋ ឬនិយាយមិនពិតថា ជនណាមួយត្រូវតែធ្វើការដើម្បីសងបំណុល។

ឈ្មួញជួញដូរប្រើប្រាស់វិធីរួមបញ្ចូលគ្នាដូចជា**ការធ្វើឲ្យភ័យខ្លាច ការបំភិតបំភ័យ ការរំលោភបំពាន និងតិចនិកផ្លូវចិត្ត** ដើម្បីគ្រប់គ្រងជនរងគ្រោះ ដូចជា៖

**ការរំលោភបំពានផ្លូវអារម្មណ៍៖** ការបន្ទាបបន្ថោកកម្មករនៅចំពោះមុខអ្នកដទៃ ការជេរប្រមាថ ការធ្វើឱ្យជនរងគ្រោះមានអារម្មណ៍ថាមានកំហុស និងការបន្ទោសពួកគេដោយសារ ស្ថានការណ៍នេះ។ ឈ្មួញជួញដូរក៏អាចអះអាងនូវឯកសិទ្ធិរបស់ពួកគេ ដោយផ្អែកលើយេនឌ័រ អាយុ ឬសញ្ជាតិដើម្បីបង្ហាញថាខ្លួនធំជាង។ ផ្ទុយទៅវិញ ឈ្មួញជួញដូរក៏អាចសរសើរកម្មករ ប្រាប់ពួកគេថាពួកគេពឹងផ្អែកលើពួកគេ ឬប្រាប់កម្មករថា ពួកគេគឺជាអ្នកដែលយកចិត្តទុកដាក់ ឬផ្តល់ការងារឱ្យពួកគេធ្វើ ដូច្នេះពួកគេគួរតែដឹងគុណឈ្មួញជួញដូរ។

**ការដាក់ឲ្យនៅឯកោ និងការត្រួតតា៖** ឈ្មួញជួញដូរអាចប្រាប់កម្មករថា ពួកគេមិនគួរនិយាយទៅកាន់អ្នកដទៃ តាមដានកម្មករជានិច្ចតាមទូរសព្ទ ឬកាមេរ៉ា ឬដាក់បង្ហាញអាវុធ និងអះអាងថាមានសិទ្ធិអនុវត្តច្បាប់ដើម្បីបំភិតបំភ័យ។ ឈ្មួញជួញដូរក៏អាចដាក់កម្រិតលើលទ្ធភាពរបស់កម្មករក្នុងការប្រើប្រាក់ដើម្បីបង្កើតភាពអាស្រ័យពឹងពាក់ដោយបង់កម្រៃតិចតួចបំផុត ឬអត់បង់សោះ។

## ការកំណត់ការជួញដូរដែលអាចកើតមាន

ការជួញដូរមនុស្សអាចកើតមាននៅក្នុងវិស័យឧស្សាហកម្មជាច្រើន រួមមាន៖

- រោងចក្រ ដូចជារោងចក្រកាត់ដេរជាដើម
- កសិដ្ឋាន ឬការងារថែសួន
- សំណង់
- ផ្ទះឯកជន (ឧ. មេដោះ និងមេផ្ទះ)
- ភោជនីយដ្ឋាន បារ សណ្ឋាគារ ឬឧស្សាហកម្មសេវាកម្មផ្សេងទៀត
- ក្លឹបកម្សាន្ត ពេស្យាចារតាមដងផ្លូវ ហាងម៉ាស្សាក្លែងបន្លំ សេវានាំភ្ញៀវ ផ្ទះបន។ល។

ជនម្នាក់អាចជាជនរងគ្រោះនៃការជួញដូរមនុស្សប្រសិនបើគាត់៖

- មិនអាចដើរហើរដោយសេរី
- មិនមានសិទ្ធិគ្រប់គ្រងលើឯកសារអត្តសញ្ញាណ ឬលុយកាក់ផ្ទាល់ខ្លួន
- មិនទទួលបានប្រាក់ឈ្នួល ឬបានប្រាក់ឈ្នួលតិចតួចបំផុត
- ធ្វើការច្រើនម៉ោងខុសពីធម្មតា
- ជំពាក់បំណុលច្រើន ឬបំណុលចេះតែកើនឡើង
- រស់នៅ ឬធ្វើការនៅក្នុងទីតាំងដែលមានសុវត្ថិភាពខ្លាំងខុសពីធម្មតា ឬមានកាមេរ៉ាច្រើន
- មានការថប់បារម្ភខុសពីធម្មតា ភ័យខ្លាច ស្តាប់បង្គាប់ធ្លាក់ទឹកចិត្ត ភ័យ ឬតានតឹង
- មានរបួសដោយគ្មានមូលហេតុ ឬឈឺ ឬមានជំងឺដែលមិនបានព្យាបាល
- បង្ហាញសញ្ញានៃការរំលោភបំពានផ្លូវកាយ ឬផ្លូវភេទ ការដាក់កំហិតលើផ្លូវកាយ ការចាប់បង្ខាំង ឬធ្វើទារុណកម្ម

## តួនាទីរបស់ក្រសួងការងាររដ្ឋញូវយ៉ក ក្នុងការជួយជនរងគ្រោះនៃការជួញដូរមនុស្ស

ក្រសួងការងារមានសិទ្ធិអំណាចក្នុងការទទួលពាក្យបណ្តឹង និងធ្វើការស៊ើបអង្កេតលើករណីរំលោភច្បាប់ការងារនៅទីក្រុងញូវយ៉ក ដូចជាប្រាក់ឈ្នួលអប្បបរមា ប្រាក់បន្ថែមម៉ោង ប្រាក់ឈ្នួលមិនទាន់បើក និងការកាត់ប្រាក់ដោយខុសច្បាប់។ ក្រុមអ្នកស៊ើបអង្កេតមកពីក្រសួងការងារមានសិទ្ធិចូល និងត្រួតពិនិត្យអាជីវកម្ម ធ្វើសម្ភាសកម្មករ និងពិនិត្យបញ្ជីប្រាក់បៀវត្សរ៍។ បុគ្គលិកនៃក្រសួងការងារត្រូវបានបណ្តុះបណ្តាលឲ្យចេះកំណត់ករណីជួញដូរដែលអាចកើតមាន។ នាយកដ្ឋានគោលនយោបាយ និងកិច្ចការជនអន្តោប្រវេសន៍សម្របសម្រួលកិច្ចខិតខំប្រឹងប្រែងប្រឆាំងការជួញដូរមនុស្សរបស់ក្រសួងការងារ រួមមាន៖

- ការផ្តល់ការបញ្ជូនបន្តទៅកាន់កម្មវិធីឆ្លើយតបទៅនឹងការជួញដូរមនុស្សរបស់រដ្ឋញ៉ូវយ៉ក
- ការផ្តល់វិញ្ញាបនបត្រសម្រាប់ទិដ្ឋាការប្រភេទ U ឬ T សម្រាប់ជនរងគ្រោះដែលមានសិទ្ធិនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរ រួមទាំងការជួញដូរមនុស្ស
- ការបង្កើនការយល់ដឹងជាសាធារណៈតាមរយៈបទបង្ហាញចុះផ្សព្វផ្សាយដល់សហគមន៍ និងទីតាំងអាជីវកម្ម

បើអ្នកចាប់អារម្មណ៍លើសេវាកម្មណាមួយរបស់យើង សូមទូរសព្ទទៅនាយកដ្ឋានអនុលោមភាព និងអប់រំ (ពីមុនហៅថា នាយកដ្ឋានគោលនយោបាយ និងកិច្ចការជនអន្តោប្រវេសន៍) តាមរយៈលេខ **877-466-9757** ឬផ្ញើអ៊ីមែលទៅ **trafficking@labor.ny.gov**។

